ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :..........៣៦២..........ក.ប/ស.ជ.ណ

## សេចក្តីជូនដំណឹង
## ស្តីពី
## ថ្ងៃឈប់ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារបានជ្រាបថា យោងតាមច្បាប់ស្តីពីការងារ និងប្រកាសរបស់ក្រសួងលេខ ៤១៦ កប/ប្រ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០១៦ សូមអស់លោក លោកស្រី អនុញ្ញាតឲ្យកម្មករនិយោជិតទាំងអស់របស់ខ្លួនឈប់សម្រាក ដោយមានប្រាក់ឈ្នួលក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុកខាងមុខនេះ ក្នុងរយៈពេលបួនថ្ងៃ គឺថ្ងៃទី១៣-១៤-១៥ និងថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០១៦ ជំនួសថ្ងៃអាទិត្យទី១៣។

ក្រសួងសូមបញ្ជាក់ថា ក្នុងករណីចាំបាច់បំផុត ដែលសហគ្រាស គ្រឹះស្ថាន មិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុកខាងមុខនេះ ម្ចាស់ នាយកសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួលជាមួយកម្មករនិយោជិតឲ្យមានការស្ម័គ្រចិត្តព្រមទាំងបែងចែកឲ្យមានពេលវេលា និងថ្ងៃឈប់សម្រាកបុណ្យបានសមស្រប។

កម្មករនិយោជិតដែលធ្វើការថ្ងៃឈប់ក្នុងព្រះរាជពិធីនេះ មានសិទ្ធិទទួលនូវប្រាក់បំណាច់បន្ថែមដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមជឿជាក់ថា អស់លោក លោកស្រី ដែលជាម្ចាស់ នាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អត្រឹមត្រូវជាពុំខាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- -ក្រសួងព្រះបរមរាជវាំង
- -គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- -គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- -សមាគមនិយោជក
- -សហព័ន្ធសហជីព កម្មករនិយោជិត "ដើម្បីជ្រាប និងអនុវត្ត"
- -កាលប្បវត្តិ និងឯកសារ